**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ០៤១ / ០៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## រូបសញ្ញាវិទ្យាស្ថាន
## វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

## រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការកែសំរួល បង្កើតផ្លាកសញ្ញាមួយចំនួន បំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការកែសម្រួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពត្រយោង ឯកសណ្ឋានការងារលេខ៤ មួកបេរេ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ ៤ និងសញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ



26 MAY 2006

- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការតម្លើងឋានៈសាលាពេទ្យកងយោធពលខេមរភូមិន្ទទៅជាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ
- តាមសំណើររបស់ វិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

**សំរេច**

**ប្រការ ១** : ត្រូវបានអនុញ្ញាតអោយប្រើប្រាស់រូបសញ្ញាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ។

**ប្រការ ២** : កំណត់រូបសញ្ញាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ដូចខាងក្រោម :

* មានព្រះខ័ន្ធខ្វែងជាមួយស្លាបចាំកាស្លាបសត្វ នៅកណ្តាលមានសៀវភៅបើកមួយ ចំកណ្តាលសៀវភៅមានរូបកាកបាទពណ៌ក្រហម ដែលផ្ទៃកខាងឈរមានឆ្នូតពណ៌ស រុំព័ទ្ធដោយសត្វពស់មួយក្បាល ។

* ខ្នាត និងទំហំ : ព្រះខ័ន្ធមានប្រវែង ៣៥ម.ម ស្លាបចាំកាស្លាបសត្វមានប្រវែង ៣៥ម.ម ទំហំសៀវភៅបើកបណ្តោយ ១៥ម.ម កំពស់ ១០ម.ម ផ្ចិតកណ្តាលសៀវភៅ០៤ម.ម ខ្នាតកាកបាទក្រហមនិមួយៗប្រវែង ៨ម.ម ទទឹង៤ម.ម ទំហំខ្លួនពស់នៅលើសញ្ញាលេខបូកត្រង់ទៅលើចំកណ្តាលមានឆ្នូតបណ្តោយប្រវែង៨ម.ម សំរាប់ពស់រុំ ពស់រុំ៣ជាន់ ក្បាលពស់លូតទៅលើ កន្ទុយពស់ចុះមកក្រោមមានទំហំ ២ម.ម ។ រូបសញ្ញាសំគាល់នេះផលិតពីលោហពណ៌មាស មានកំរាស់ ១,៥ម.ម ។

* រូបសញ្ញានេះសំរាប់ពាក់នៅលើកអាវ នៃឯកសណ្ឋានលេខ ២ - ៣ - ៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត ស្រោមលិខិត សញ្ញាប័ត្រ លិខិតបញ្ជាក់ការសិក្សា នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ និងវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ។

**ប្រការ ៣** : អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការកងឯកភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ់

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងការពារជាតិ
- ទីប្រឹក្សាក្រសួងការពារជាតិ
- អគ្គបញ្ជាការដ្ឋាន
- ដូចប្រការ ៣
(ដើម្បីជូនជ្រាប និងអនុវត្ត)
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## សញ្ញាសំគាល់វិទ្យាស្ថាន វិទ្យាសាស្ត្រ សុខាភិបាល កងយោធពលខេមរភូមិន្ទ



**រូបភាព :** មានព្រះខ័នខ្មែរជាមួយស្លាបប៉ាកការស្លាបសត្វ នៅកណ្តាលមានសៀវភៅបើកមួយ ចំកណ្តាល សៀវភៅ មានរូបកាកបាទពណ៌ក្រហមដែលមានផ្នែកខាងឈរមានធ្នូតពណ៌ស រុំព័ទ្ធដោយសត្វពស់មួយក្បាល ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១,៥ មម ។

**ខ្នាត :** ព្រះខ័នមានប្រវែង ៣៥ មម ស្លាបប៉ាកាស្លាបសត្វ ប្រវែង ៣៥មម ទំហំសៀវភៅបើក បណ្តោយ១៥មមកំពស់១០មម ផ្ចិតកណ្តាលសៀវភៅ ០៤មម ខ្នាតកាកបាទក្រហមនិមួយៗប្រវែង ៨មម ទទឹង ៤មម ទំហំខ្លួនពស់ នៅលើសញ្ញាលេខបូកត្រង់ទៅលើចំកណ្តាលមានឆ្នូតបណ្តោយប្រវែង៨ មម សំរាប់ពស់រុំ ពស់រុំពាដាន់ ក្បាលពស់លូតទៅលើ កន្ទុយពស់ចុះមកក្រោម មាន ទំហំ ២មម ។